# សុន្ទរកថាបើកកម្មវិធី

# ឯកឧត្តម ជា ចេដ្ឋ

## ប្រធានគណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា

ក្នុងកិច្ចប្រជុំបង្ហាញគម្រោងស្តីពី

**"ការវាយតម្លៃផលប៉ះពាល់លើប្រទេសកម្ពុជាបន្ទាប់ពីបញ្ចប់កិច្ចព្រមព្រៀង**

**ស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់"**

ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦, សណ្ឋាគារ INTERCONTINENTAL

**ជាកិច្ចចាប់ផ្តើម ខ្ញុំសូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ព្រមទាំង ភ្ញៀវជាតិ និងអន្តរជាតិ ទាំងអស់ដែលមានវត្តមាននៅទីនេះ ។**

ក្នុងនាមខ្ញុំប្រធានគណៈកម្មការទី២ នៃព្រឹទ្ធសភា ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ខ្ញុំបាទមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានអញ្ជើញមកចូលរួមជាវាគ្មិនកិត្តិយស ថ្លែងសុន្ទរកថាបើកកម្មវិធី ក្នុងកិច្ចប្រជុំបង្ហាញគម្រោង និងពិភាក្សាស្តីពី **"ការវាយតម្លៃផលប៉ះពាល់លើប្រទេសកម្ពុជា បន្ទាប់ពីបញ្ចប់កិច្ចព្រមព្រៀងស្តីពី វាយនភ័ណ្ឌ និងសំលៀកបំពាក់"** ដែលរៀបចំឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា **(EIC)** នាពេលនេះ ។

ខ្ញុំក៏សូមកោតសរសើរ ដោយស្មោះចំពោះកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលបានចូលរួមយ៉ាងច្រើនក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ហើយជាក់ស្តែងគម្រោងដែលយើងនឹងពិភាក្សាគ្នា នាថ្ងៃនេះក៏បានទទួលការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំតំបន់នៅទីក្រុង Colombo (UNDP-RCC)។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ផងដែរ ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលមានវត្តមាននៅទីនេះ។

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០មក ឧស្សាហកម្មកាត់ដេរ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជាយើង។ ឧស្សាហកម្មកាត់ដេរបានស្រូបយកប្រមាណ ៣០% នៃវិនិយោគទុនបរទេស ហើយបានបង្កើតការងារយ៉ាងច្រើនជូនប្រជាពលរដ្ឋ ក្រីក្រនៅតាមទីជនបទនានា។ បច្ចុប្បន្ន មានប្រជាពលរដ្ឋខ្មែរលើសពី ៣០ម៉ឺននាក់ ដែលកំពុងបំរើការដោយផ្ទាល់ នៅក្នុងវិស័យកាត់ដេរ ហើយប្រជាជនជាច្រើនពាន់នាក់ទៀតដែលទទួលផលប្រយោជន៍ពីឧស្សាហកម្មកាត់ដេរនេះ ដោយធ្វើការនៅក្នុងឧស្សាហកម្មគាំទ្រ និងទទួលប្រាក់បញ្ញើរពីកម្មករកាត់ដេរ។

ជាការពិតណាស់ ទោះមានការបញ្ចប់កូតានាចុងឆ្នាំ ២០០៤ ក៏ដោយ ក៏ឧស្សាហកម្មកាត់ដេរកម្ពុជានៅតែទទួលបានជោគជ័យគួរអោយកត់សំគាល់ ដោយការនាំចេញសំលៀកបំពាក់នៅតែបន្តកើនឡើង។ នៅក្នុងឆ្នាំ ២០០៥ ការនាំចេញសំលៀកបំពាក់បានកើនឡើងរហូតដល់ ២,២ពាន់លានដុល្លា គឺស្មើនឹង ១០% លើសឆ្នាំ ២០០៤។ គម្រោងវិនិយោគក្នុងវិស័យកាត់ដេរចំនួន ៥៣ បន្ថែមទៀតត្រូវបានអនុម័តនៅក្នុង ឆ្នាំ ២០០៥ បន្ទាប់ពីបញ្ចប់ កិច្ចព្រមព្រៀងវាយនភ័ណ្ឌពហុសរសៃអំបោះ (MFN) ឬកូតានៅចុងឆ្នាំ ២០០៤។ នេះគឺដោយសារតែប្រទេសកម្ពុជាយើង គោរពច្បាប់ការងារបានល្អទៅតាមស្តង់ដារពលកម្មអន្តរជាតិ និងការគាំទ្រលើកទឹកចិត្តពីរាជរដ្ឋាភិបាល។ នៅចុងឆ្នាំ ២០០៤ យើងមានការព្រួយបារម្ភជាខ្លាំងអំពី អនាគតរបស់វិស័យ ឧស្សាហកម្មកាត់ដេរ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវវិធានការណ៍ជាច្រើនក្នុងគោលបំណង ជួយលើកស្ទួយវិស័យមួយនេះ ដូចជា ការលើកលែងពន្ធសំរាប់ការនាំចូលវត្ថុធាតុដើម និងការលើកលែងពន្ធលើប្រាក់ចំណេញដល់រោងចក្រកាត់ដេរ។

ជាមួយគ្នានោះដែរ ព្រះរាជាណាចក្រកម្ពុជាយើងក៏បានអនុវត្តនូវគោលនយោបាយ កំណែទម្រង់ពាណិជ្ជកម្មជាច្រើន ពង្រឹង និងបង្កើតច្បាប់បន្ថែមទៀត ក្នុងគោលបំណងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងស្រុក ក៏ដូចជាទាក់ទាញវិនិយោគិនបរទេសឱ្យចូលមកធ្វើការវិនិយោគនៅក្នុងស្រុក។ ការកាត់បន្ថយការិយាធិបតេយ្យ និងការសំរួលពាណិជ្ជកម្ម មានការរីកចំរើនគួរកត់សំគាល់។ ជាលទ្ធផល ដែលធ្វើឱ្យយើងភ្ញាក់ផ្អើល និងមានមោទនភាពនោះគឺកំណើនសេដ្ឋកិច្ចនៅក្នុងឆ្នាំ ២០០៥ ដែលមានរហូតដល់ទៅ ១៣.៤% គឺកើនឡើងលើសពីការ រំពឹងទុក។

គួរបញ្ជាក់ផងដែរថា ភាពប្រកួតប្រជែងរបស់កម្ពុជាមានភាពប្រសើរឡើង បើយោងទៅតាមការវាយតំលៃរបស់អង្គការវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) ដែលចេញផ្សាយនាពេលថ្មីៗនេះ។ ភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា ទទួលបានចំណាត់ថ្នាក់ទី ១០៣ ក្នុងចំណោម ១២៥ ប្រទេស សម្រាប់ឆ្នាំ ២០០៦ ដោយធៀបនឹងចំណាត់ថ្នាក់ទី ១១១ សំរាប់ឆ្នាំ ២០០៥។ ទោះជាយ៉ាងនេះក្តី កម្ពុជានៅមានភាពទន់ខ្សោយនៅឡើយ បើធៀបទៅនឹងបណ្តាប្រទេសមួយចំនួនក្នុងពិភពលោក រួមទាំង ប្រទេសជាដៃគូរប្រកួតប្រជែងរបស់ខ្លួន ដូចជាប្រទេសចិន ឥណ្ឌា ឥណ្ឌូនេស៊ី និងប្រទេសវៀតណាមជាដើម។ អ្វីដែលយើងគួរយកចិត្តទុកដាក់នោះ គឺថាសមត្ថភាពរបស់ប្រទេសកម្ពុជាយើង នៅមានកំរិតនៅឡើយ ក្នុងការប្រកួត ប្រជែងដោយស្មើភាពជាមួយប្រទេស ដទៃទៀតក្រោមសមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ជាក់ស្តែង សមាជិកភាពរបស់ប្រទេសវៀតណាម នៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) អាចនឹងមានឥទ្ធិពលដល់ប្រទេសកម្ពុជាយើង។

ទាក់ទងនឹង វិស័យហិរញ្ញវត្ថុវិញ យើងហាក់ដូចជានៅទន់ខ្សោយនៅឡើយ ដែលទាមទារនូវការជំរុញបន្ថែមទៀត។ កន្លងមក យើងបានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការលើកកំពស់វិស័យនេះឱ្យរីកចំរើនទៅមុខជាលំដាប់ ដើម្បីជួយបង្កលក្ខណៈងាយស្រួលដល់ប្រតិបត្តិការពាណិជ្ជកម្មនានា។ ទាក់ទិននឹងវិស័យហិរញ្ញវត្ថុនេះ

ធនាគារជាតិបានដាក់ចេញនូវគោលនយោបាយមួយចំនួន សំដៅបង្កើននូវទំនុកចិត្ត ពីសំណាក់ភ្នាក់ងារសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។ ជាក់ស្តែង នៅដើមឆ្នាំ ២០០៦ រាជរដ្ឋាភិបាល បានប្រកាសថាជា "ឆ្នាំនៃមីក្រូហិរញ្ញវត្ថុ "។ ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកទាំងអស់ ត្រូវបានលើកស្ទួយ។ មកទល់នឹងពេលបច្ចុប្បន្ន ស្ថាប័ន មីក្រូហិរញ្ញវត្ថុមានចំនួនសរុប ១៦ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួននេះហាក់ ដូចជានៅតិចតួចនៅឡើយ បើប្រៀបធៀបទៅនឹងតម្រូវការជាក់ស្តែង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ជាទីគោរព!**

ទាំងនេះមានន័យថា យើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីជំរុញភាពប្រកួតប្រជែងរបស់កម្ពុជា។ តាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ប្រទេសកម្ពុជាត្រូវកាត់បន្ថយអត្រានៃភាពក្រីក្រ ឱ្យបានពាក់កណ្តាលនៅក្នុងឆ្នាំ ២០១៥ ពោលគឺមកនៅត្រឹម១៩.៥%។ ដើម្បីឈានឱ្យដល់គោលដៅនេះ ចាំបាច់យើងត្រូវរក្សាឱ្យបាន នូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើតការងារបន្ថែមសម្រាប់ប្រជាពលរដ្ឋ ក្នុងគោលបំណងកាត់បន្ថយអត្រានិកម្មភាពនៅក្នុងស្រុក។

ការងារដែលផ្តល់ឱ្យដោយវិស័យកាត់ដេរ អាចស្រូបយកកំលាំងពលកម្ម បានប្រមាណតែ ៥% ប៉ុណ្ណោះ។ ដូច្នេះការពឹងផ្អែកតែទៅលើវិស័យមួយមុខ ពិតជាពុំទាន់អាចឆ្លើយតបនឹងតម្រូវការការងារនាពេលបច្ចុប្បន្ននៅឡើយទេ ដែលប្រមាណជាង ២៥០.០០០ នាក់ត្រូវបានប៉ាន់ស្មានថាចូលក្នុងទីផ្សារការងាររៀងរាល់ឆ្នាំ។ ការពង្រីកការងារទៅតាមវិស័យផ្សេងៗទៀតពិតជាមានសារៈសំខាន់ណាស់ ក្នុងការចូលរួមចំណែកសម្រេចឱ្យបាន នូវស្ថេរភាពការងារសម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាឈាន ឱ្យដល់គោលដៅសហស្សវត្សរ៍របស់ប្រទេសកម្ពុជា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចប្រជុំបង្ហាញគម្រោង និងកិច្ចពិភាក្សានាថ្ងៃនេះ នឹងផ្តល់ជាគំនិតល្អៗបន្ថែមទៀតដែលអាចជួយជម្រុញឱ្យប្រទេសកម្ពុជាយើងមានការអភិវឌ្ឍទៅមុខឆាប់រហ័សដូចប្រទេសដទៃទៀតនៅលើសកលលោក។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់** អោយជួបប្រទះតែនឹងសុភមង្គល និងការរីកចំរើនគ្រប់ពេលវេលា។

សូមជូនពរអោយការអនុវត្ត គម្រោងទាំងមូលទទួលបានជោគជ័យដ៏ត្រចះត្រចង់ នឹងនាំមកនូវផ្លែផ្កាល្អសម្រាប់ប្រទេសកម្ពុជា។

**សូមអរគុណ!**